# លិខិតជូនដំណឹង និងការយល់ព្រមចំពោះការវាយតម្លៃ/ការប៉ាន់ប្រមាណលើកដំបូង

**គោលបំណង៖** ដើម្បីផ្តល់លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់មាតាឬបិតានៅពេលការវាយតម្លៃ/ការប៉ាន់ប្រមាណលើកដំបូង ត្រូវបានស្នើសុំ និងទទួលការយល់ព្រមពីមាតាបិតាដើម្បីអនុវត្តការវាយតម្លៃ/ការប៉ាន់ប្រមាណលើកដំបូងដែលបានស្នើសុំ។

| **ឈ្មោះកូន** | **ថ្ងៃខែឆ្នាំកំណើត** | **អ្នកសម្របសម្រួលធនធានគ្រួសារ** |
| --- | --- | --- |
| | | |

**មូលហេតុចំពោះលិខិតដំណឹង**

កម្មវិធី ESIT តម្រូវឱ្យផ្តល់ជូនលោកអ្នកនូវលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដែលមានរយៈពេលសមរម្យ មុនការអនុវត្តសកម្មភាពនៃការវាយតម្លៃ និងការប៉ាន់ប្រមាណ។ វាតម្រូវឱ្យលោកអ្នកផ្តល់ជូនការយល់ព្រមជាលាយលក្ខណ៍អក្សរ ដែលបានជូនដំណឹងសម្រាប់សកម្មភាពទាំងនេះតាមរយៈហត្ថលេខារបស់អ្នកខាងក្រោម។ គោលបំណងនៃការវាយតម្លៃ និងការប៉ាន់ប្រមាណ គឺដើម្បីទទួលបានព័ត៌មានអំពីកូនរបស់អ្នកពីលោកអ្នក និងមនុស្សផ្សេងទៀតដែលអ្នកស្នើសុំឱ្យចូលរួម; ផ្តល់ជូនព័ត៌មានបន្ថែមដល់ក្រុមគ្រួសាររបស់អ្នកអំពីការវិវត្តន៍កូនរបស់អ្នក; កំណត់ភាពខ្លាំងតែមួយគត់ និងតម្រូវការរបស់កូននិងសេវាកម្មរបស់អ្នក ដែលអាចសមស្របដើម្បីបំពេញតម្រូវការទាំងនោះ; កំណត់ថាតើកូនរបស់អ្នកមានសិទ្ធិទទួលបានកម្មវិធី ESIT ឬអត់;

ហើយប្រសិនបើកូនរបស់អ្នកមានសិទ្ធិស្របច្បាប់ចំពោះកិច្ចព្រមព្រៀង និងការចូលរួមរបស់អ្នក បង្កើតផែនការសេវាកម្មក្រុមគ្រួសារដែលមានលក្ខណៈបុគ្គលដែលសរសេរជាលាយលក្ខណ៍អក្សរ (IFSP) ។ ហើយនេះជារបាយការណ៍របស់អ្នកអំពីលិខិតជូនដំណឹងនោះ។

*ការយល់ព្រម"មានន័យថា៖ (1) លោកអ្នកទទួលបានដំណឹងយ៉ាងពេញលេញអំពីព័ត៌មានទាំងអស់ដែលពាក់ព័ន្ធនឹងសកម្មភាព ដែលក្នុងនោះការយល់ព្រមណាមួយត្រូវបានស្វែងរកជាភាសាកំណើតរបស់អ្នក (លុះត្រាតែមិនអាចធ្វើបានតាមលក្ខណៈច្បាស់លាស់ដើម្បីអនុវត្តដូច្នេះ) ឬរបៀបនៃការប្រាស្រ័យទាក់ទង ដែលរួមមានទាំងភាសាប្រើសញ្ញា អក្សរសម្រាប់មនុស្សខ្វាក់ ឬឬការប្រាស្រ័យទាក់ទងដោយផ្ទាល់មាត់ដែលសមស្រប; (2) ដែលលោកអ្នកយល់ដឹងនិងយល់ព្រមជាលាយលក្ខណ៍អក្សរចំពោះការអនុវត្តសកម្មភាពដែលត្រូវបានស្វែងរក; (3) ការយល់ព្រមនេះពិពណ៌នាអំពីសកម្មភាពនិងរាយបញ្ជីកត់ត្រាអន្តរាគមន៍ចាប់ផ្តើមដំបូង (ប្រសិនបើមាន) ដែលនឹងត្រូវបញ្ចេញឱ្យដឹងព័ត៌មានទៅអ្នកណាដែលត្រូវផ្សព្វផ្សាយឱ្យដឹង; និង (4) ការផ្តល់ជូនការយល់ព្រមរបស់អ្នកជាការស្ម័គ្រចិត្ត ហើយអាចដកចេញវិញដោយសរសេរជាលាយលក្ខណ៍អក្សបានគ្រប់ពេលវេលា។ ប្រសិនបើលោកអ្នកដកចេញការយល់ព្រមនោះ វាមិនមានសកម្មភាពឡើងវិញឡើយ (វាមិនអនុវត្តចំពោះសកម្មភាពដែលបានកើតឡើងមុនការយល់ព្រមនេះត្រូវបានដកចេញវិញឡើយ)។*

**វិធានការដែលបានស្នើសុំ**

ការវាយតម្លៃនិងការប៉ាន់ប្រមាណនឹងត្រូវអនុវត្តដោយបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់យ៉ាងតិចចំនួនពីរនាក់មកពីផ្នែកអប់រំផ្សេងគ្នា (ឬអ្នកជំនាញដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពីផ្នែកអប់រំចំនួនពីរ) ដោយស្របតាមគោលនយោបាយនិងនីតិវិធីនៃកម្មវិធី ESIT ។

ការចូលរួមរបស់អ្នកជាសមាជិកនៃក្រុមការងារវាយតម្លៃ ត្រូវបានលើកទឹកចិត្តយ៉ាងខ្លាំង។ លោកអ្នកយល់ដឹងអំពីកូនរបស់អ្នកយ៉ាងល្អបំផុត ហើយអាចផ្តល់ព័ត៌មានសំខាន់ៗអំពីកូនរបស់អ្នក។ ការវាយតម្លៃនិងការប៉ាន់ប្រមាណគឺជាទស្សនៈទូលំទូលាយមួយអំពីរបៀបដែលកូនរបស់អ្នកកំពុងអនុវត្តមុខវិជ្ជាផ្នែកការយល់ដឹង ចលនាដៃជើងនិងរាងកាយ ជំនាញប្រើដៃ ការប្រាស្រ័យទាក់ទង ការវិវត្តន៍ផ្នែកសម្របខ្លួន ផ្លូវចិត្តនិងសង្គម ដូចជាចក្ខុឬការមើលឃើញ និងការស្តាប់ផងដែរ។ លទ្ធផលបង្ហាញអំពីរបៀបដែលកូនរបស់អ្នកកំពុងអនុវត្តនៅគ្រប់មុខវិជ្ជាទាំងនេះ ហើយថាតើកូនរបស់អ្នក មានសិទ្ធិទទួលបានសេវាកម្ម ESIT ឬអត់។

**ការពិពណ៌នា**

ការវាយតម្លៃដែលបានស្នើសុំ នឹងរាប់បញ្ចូលនូវនីតិវិធីជាច្រើន ដែលរួមមានទាំងការគ្រប់គ្រងវិធីសាស្ត្រនៃវាយតម្លៃ ការទទួលយកប្រវត្តិកុមារ ការសម្ភាសន៍ឪពុកម្តាយ ការប្រមូលព័ត៌មានពីសមាជិកគ្រួសារ អ្នកមើលថែទាំ អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ឬអ្នកជំនាញផ្សេងទៀត និង ការពិនិត្យឡើងវិញនូវកំណត់ត្រាវេជ្ជសាស្ត្រ អប់រំ ឬកំណត់ត្រាផ្សេងទៀត។ នីតិវិធីវាយតម្លៃដែលបានស្នើសុំនឹងកំណត់ភាពខ្លាំងតែមួយគត់ និងតម្រូវការ និងសេវាកម្មអន្តរាគមន៍ចាប់ផ្តើមដំបូងដែលដែលសមរម្យរបស់កូនអ្នក។ ការវាយតម្លៃ**នឹង**រាប់បញ្ចូល៖ ការពិនិត្យឡើងវិញនូវលទ្ធផលវាយតម្លៃ; ការត្រួតពិនិត្យផ្ទាល់ខ្លួនអំពីកូន ការកំណត់អត្តសញ្ញាណតម្រូវការរបស់កូនចំពោះមុខវិជ្ជាអភិវឌ្ឍនីមួយៗតាមរយៈការប្រើនីតិវិធីវាយតម្លៃជាផ្លូវការនិងមិនផ្លូវការ។ អ្នកផ្តល់សេវាកម្មនៃកម្មវិធី ESIT នឹងពិភាក្សាជាមួយលោកអ្នកអំពីវិធីសាស្ត្រដែលពួកគេនឹងប្រើប្រាស់សម្រាប់ការវាយតម្លៃ និងការប៉ាន់ប្រមាណនេះ។ ការវាយតម្លៃ និងការប៉ាន់ប្រមាណនេះនឹងត្រូវផ្តល់ជូនដោយឥតគិតថ្លៃលោកអ្នកឡើយ។ លទ្ធផលត្រូវបានរក្សាទុកនៅក្នុងកំណត់ត្រាអន្តរាគមន៍ចាប់ផ្តើមដំបូងរបស់កូនអ្នក។ គ្មានព័ត៌មានអំពីការវាយតម្លៃ និងការប៉ាន់ប្រមាណនឹងត្រូវចែករំលែកជាមួយនរណាម្នាក់ ឬទីភ្នាក់ងារណាមួយក្រៅកម្មវិធី ESIT ឡើយ លុះត្រាតែលោកអ្នកផ្តល់ជូនការយល់ព្រមជាលាយលក្ខណ៍អក្សរ**ដើម្បីធ្វើដូច្នេះ**។ ក្រុមការងារកម្មវិធី IFSP នឹងកំណត់ថាតើកូនរបស់អ្នកមានសិទ្ធិស្របច្បាប់ឬអត់ ហើយនឹងផ្តល់លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុន ដែលរួមមានទាំងសិទ្ធិរបស់អ្នកដើម្បីជំទាស់អំពីការកំណត់ភាពមានសិទ្ធិស្របច្បាប់។

**ការកំណត់ពេលវេលា** *កំណត់កាលបរិច្ឆេទកូនរបស់អ្នកដែលបានបញ្ជូនទៅកម្មវិធី ESIT ។* [ ]

Tក្រុមការងារពហុមុខវិជ្ជានឹងបំពេញការវាយតម្លៃនិងការប៉ាន់ប្រមាណ ហើយបើកូនរបស់អ្នកមានសិទ្ធិស្របច្បាប់ ហើយអ្នកយល់ព្រមនោះ ការអភិវឌ្ឍផែនការសេវាកម្មក្រុមគ្រួសារដែលមានលក្ខណៈបុគ្គល (IFSP) ត្រូវតែបញ្ចប់ក្នុងរយៈពេល 45 ថ្ងៃនៃថ្ងៃប្រតិទិនដោយគិតចាប់ពីថ្ងៃដែលកូនរបស់អ្នកបានបញ្ជូនទៅ។ ប្រសិនបើគ្រួសាររបស់អ្នកត្រូវការពេលបន្ថែមលើសពី 45 ថ្ងៃនោះ វាមានសារៈសំខាន់ណាស់ដែលថាលោកអ្នកត្រូវប្រាប់អ្នកសម្របសម្រួលធនធានគ្រួសាររបស់អ្នក។ កម្មវិធី IFSP ជាផែនការរៀបចំជាលាយលក្ខណ៍អក្សរដែលបានអភិវឌ្ឍដោយភាពជាដៃគូជាមួយក្រុមគ្រួសារនិងអ្នកជំនាញរបស់អ្នក ដើម្បីបំពេញតម្រូវការដែលកំពុងបន្តដំណើរការសម្រាប់កូនអ្នកនិងក្រុមគ្រួសាររបស់អ្នក។ វាអាចផ្លាស់ប្តូរបានគ្រប់ពេលវេលា។ កម្មវិធី IFSP ត្រូវបានសរសេរជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ប្រសិនបើកូនរបស់អ្នកមានសិទ្ធិស្របច្បាប់ចំពោះសេវាកម្ម។

**ការទទួលស្គាល់ និងរបាយការណ៍អំពីការយល់ព្រម**

**ខ្ញុំបាទ/នាងខ្ញុំបានទទួលឯកសារថតចម្លងមួយច្បាប់នៃសិទ្ធិ និងការការពារសុវត្ថិភាពតាមនីតិវិធីរបស់ខ្ញុំ ដែលស្ថិតក្រោមផ្នែក C នៃ IDEA (កម្មវិធីគាំទ្រ កុមារនិងទារកចាប់ផ្តើមដំបូង** ***ច្បាប់ស្តីពីការអប់រំបុគ្គលដែលមានពិការភាព ផ្នែកC***

*អក្សរដំបូងនៃ ឈ្មោះមាតាឬបិតា*

| |
|---|
| |

***ការការពារសុវត្ថិភាពតាមនីតិវិធី [សិទ្ធិមាតាបិតា])* ដោយមានលិខិតជូនដំណឹងនេះ។** សិទ្ធិនិងនីតិវិធីការពារសិទ្ធិតាមនីតិវិធីទាំងនេះ បានពន្យល់ខ្ញុំ ហើយខ្ញុំយល់ដឹងអំពីសិទ្ធិនិងនីតិវិធីទាំងនេះ។ ខ្ញុំបាទ/នាងខ្ញុំ យល់ថាការយល់ព្រមរបស់ខ្ញុំជាការស្ម័គ្រចិត្ត ហើយថាខ្ញុំអាចជ្រើសរើសមិនឱ្យវាយតម្លៃកូនខ្ញុំបានគ្រប់ពេលវេលា បើទោះជាក្រោយពីការចុះហត្ថលេខាលើសំណុំបែបបទនេះក៏ដោយ។ ខ្ញុំបាទ/នាងខ្ញុំ យល់ថាអ្វីដែលខ្ញុំជ្រើសរើសមិនយល់ព្រមចំពោះការវាយតម្លៃនិងការប៉ាន់ប្រមាណនេះ កូនខ្ញុំនឹងមិនត្រូវបានវាយតម្លៃឬប៉ាន់ប្រមាណឡើយ ហើយមិនអាចទទួលបានសេវាអន្តរាគមន៍ចាប់ផ្តើមដំបូងដែលស្ថិតក្រោមកម្មវិធី ESIT ឡើយ។។

| | | |
|---|---|---|
| ☐ **ខ្ញុំអនុវត្ត** | ☐ **ខ្ញុំមិនអនុវត្ត** | ផ្តល់ជូនការយល់ព្រមដែលបានជូនដំណឹងរបស់ខ្ញុំចំពោះកម្មវិធី ESIT ដើម្បីអនុវត្តសកម្មភាពនានាដែលបានពិពណ៌នាខាងលើ |

| សរសេរអក្សរពុម្ពឈ្មោះរបស់មាតាឬបិតា | |
|---|---|
| ហត្ថលេខាមាតាឬបិតា | កាលបរិច្ឆេទ |
| បានទទួលដោយឈ្មោះ/ឋានៈ/ទីភ្នាក់ងារ | កាលបរិច្ឆេទ |

*ឯកសារភ្ជាប់៖ ការជួយគាំទ្រចាប់ផ្តើមដំបូងសម្រាប់កម្មវិធីកុមារនិងទារក ច្បាប់ស្តីពីការអប់រំបុគ្គលដែលមានពិការភាព (IDEA) ផ្នែក C ការការពារសុវត្ថិភាពតាមនីតិវិធី [សិទ្ធិមាតាបិតា]*
*កំណត់សម្គាល់៖ មាតាបិតាទទួលបានឯកសារថតចម្លងមួយច្បាប់ពីសំណុំបែបបទនេះ និងឯកសារថតចម្លងដែលមានចុះហត្ថលេខា ត្រូវរាប់បញ្ចូលក្នុងកំណត់ត្រាអន្តរាគមន៍ចាប់ផ្តើមដំបូងរបស់កុមារ។*